## ឧបសម្ព័ន្ធ ១

## ប្រវត្តិនីតិវិធីរហូតដល់បណ្តឹងឧទ្ធរណ៍

១. នៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១០ មេធាវីការពារក្តីបានដាក់ញត្តិផ្សេងទៀតរបស់លោក អៀង សារី ស្តីពីព្រំដែនកម្រិតលទ្ធភាពអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អ.វ.ត.ក នៅចំពោះមុខ ក.ស.ច.ស [១] រួមទាំងឧបសម្ព័ន្ធគាំទ្រទៀតផង[២] ។ មេធាវីការពារក្តីបានអះអាងថា បទចោទអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលធ្វើឡើងចំពោះជនជាប់ចោទ នៅ អ.វ.ត.ក ត្រូវតែអនុលោមតាមនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចបានកំណត់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងពេលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដើម្បីកុំឱ្យមានការរំលោភបំពានដល់គោលការណ៍នីត្យានុកូលភាព[៣]។ មេធាវីការពារក្តីបានលើកទឡ្ហីករណ៍ថា ចំណងទាក់ទងនៃអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធ គឺជាលក្ខខណ្ឌកំណត់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងអំឡុងពេលនៃយុត្តាធិការរបស់ អ.វ.ត.ក ប្រសិនបើ អ.វ.ត.ក មានយុត្តាធិការក្នុងការជំនុំជម្រះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ[៤]។ ឧបសម្ព័ន្ធនេះបានពន្យល់ពីប្រភពដើមនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងធាតុផ្សំរួម នៅមុន និងបន្ទាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[៥]។ ក.ស.ព មិនបានឆ្លើយតបទេ។

២. នៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមនៃសំណុំរឿង ០០១ [៦] ។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេច*ដោយមិនស្នើសុំយោបល់ពីភាគីពាក់ព័ន្ធ* (*sua*

---

[១] ញត្តិផ្សេងទៀតរបស់លោក អៀង សារី ស្តីពីព្រំដែនកម្រិតលទ្ធភាពអនុវត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅ អវតក ("ញត្តិ") ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារលេខ D378/2។

[២] ញត្តិផ្សេងទៀតរបស់លោក អៀង សារី ស្តីពីព្រំដែនកម្រិតលទ្ធភាពអនុវត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅ អវតក ឧបសម្ព័ន្ធ ៖ ខ្លឹមសារសង្ខេបនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការវិវត្តនៃឧក្រិដ្ឋទាំងនេះក្នុងយុត្តិសាស្ត្រអន្តរជាតិ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារលេខ D378/2.2 ("ឧបសម្ព័ន្ធ")។

[៣] ញត្តិ, កថាខណ្ឌ ៥។

[៤] *ដូចខាងលើ*, កថាខណ្ឌ ៨-៩។

[៥] ឧបសម្ព័ន្ធញត្តិ, កថាខណ្ឌ ៣-២១។

[៦] សំណុំរឿង *កាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អជសដ, សាលក្រម, ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារលេខ E188 ("សាលក្រម *ឌុច*")។

*sponte*)[៧] ថា ចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធមិនមែនជាលក្ខខណ្ឌចាំបាច់នៃធាតុផ្សំមួយនៃឧក្រិដ្ឋកម្មនានាប្រឆាំងនឹងមនុស្សជាតិក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ទេ ហើយថា មាត្រា ៥ នៃច្បាប់បង្កើត អ.វ.ត.ក ស្របគ្នានឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមានជាធរមាននៅក្នុងអំឡុងពេលនោះ[៨] ។ ដោយមិនបានទទួលយោបល់លើបញ្ហានេះពីភាគីអង្គជំនុំជម្រះសាលាដំបូងបានសម្រេចលើចំណងទាក់ទងនៃជម្លោះប្រដាប់អាវុធ ដែលការធ្វើដូច្នេះបង្កើតឲ្យមានករណីយុត្តិសាស្ត្រ ដែលមិនចងកាតព្វកិច្ចសម្រាប់ធាតុផ្សំឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងសំណុំរឿងនានានៅ អ.វ.ត.ក នាពេលអនាគត។ ដើម្បីសម្រេចថា ចំណងទាក់ទងនៃជម្លោះប្រដាប់អាវុធក្នុងច្បាប់ទំនៀមទម្លាប់ មិនមានអត្ថិភាពក្នុងអំឡុងពេលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩, អង្គជំនុំជម្រះសាលាដំបូងបានពឹងផ្អែកលើ ៖ **ក.** ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ឆ្នាំ ១៩៤៥ **ខ.** អនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឆ្នាំ ១៩៤៨ **គ.** សេចក្តីព្រាងក្រមស្តីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខមនុស្សជាតិរបស់គណៈកម្មាធិការច្បាប់អន្តរជាតិ ឆ្នាំ ១៩៥៤ **ឃ.** អនុសញ្ញាស្តីពីភាពមិនអាចអនុវត្តបាននៃអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឆ្នាំ ១៩៦៨ **ង.** អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបនិងការផ្តន្ទាទោសលើឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍ ឆ្នាំ ១៩៧៣ និង **ច.** អង្គជំនុំជម្រះនានាបច្ចុប្បន្ន[៩]។

៣. នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០ ក.ស.ព បានដាក់ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៦៦[១០] ។ ក.ស.ព មិនបានបញ្ចូលចំណងទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធនៅ

---

[៧] Máximo Langer, *From Legal Transplants to Legal Translations: The Globalization of Plea Bargaining and the Americanization Thesis in Criminal Procedure,* 1 HARV. INT'L. L. J. 1, 13 (2004): "ភាគីសំខាន់ៗក្នុងដំណើរការនីតិវិធី ... មានអំណាច និងទំនួលខុសត្រូវលើដំណើរការនីតិវិធីផ្សេងៗគ្នា នៅក្នុងប្រព័ន្ធនីមួយៗ។ ឧទាហរណ៍ ... អ្នកធ្វើសេចក្តីសម្រេចលើផ្នែកស៊ើបអង្កេត ក្នុងឋានៈជាអ្នកស៊ើបអង្កេតសកម្ម មានអំណាចលើនីតិវិធី ឧទាហរណ៍ ការបំពេញការងារដោយមិនចាំបាច់ស្នើសុំសំណើពីភាគីផ្សេងៗ ច្រើនជាងអ្នកធ្វើសេចក្តីសម្រេចលើសវនាការតទល់ក្តី"។

[៨] សាលក្រម *ឌុច*, កថាខណ្ឌ ២៩០។

[៩] *ដូចខាងលើ*, កថាខណ្ឌ ២៩១ ដល់ ៩២។

[១០] ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០ ឯកសារលេខ D390។

ក្នុងការពិនិត្យឡើងវិញលើលក្ខខណ្ឌតម្រូវទូទៅពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ស្របតាមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ទេ[១១]។

៤. នៅថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១០ មេធាវីការពារក្តីបានដាក់ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម[១២]។ មេធាវីការពារក្តីបានបញ្ជាក់ម្តងទៀតថា "ការអនុវត្តរបស់រដ្ឋ និង *សច្ចាធារណ៍នីត្យានុគោលភាព (opinio juris)* បង្ហាញថា ចំណងទាក់ទងរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធជាអន្តរជាតិ គឺជាលក្ខខណ្ឌតម្រូវមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩"[១៣]។

៥. នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ក.ស.ច.ស បានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០២ ដោយដកលក្ខខណ្ឌតម្រូវពីទំនាក់ទំនងរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[១៤]។

៦. នៅថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១០ មេធាវីការពារក្តីបានដាក់បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ[១៥]។ មេធាវីការពារក្តីបានសន្និដ្ឋានថា ក.ស.ច.ស មានកំហុសឆ្គងដោយខកខានពុំបានពន្យល់ថា ចំណងទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ គឺជាលក្ខខណ្ឌតម្រូវមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អ.វ.ត.ក ហើយបានបញ្ជាក់គោលជំហរជាថ្មីម្តងទៀតថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានបញ្ចូលចំណងទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធអន្តរជាតិ ក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[១៦]។

---

[១១] *ដូចខាងលើ,* កថាខណ្ឌ ១២៤២ ដល់ ៥១; *មើលផងដែរ* ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៥។

[១២] ចម្លើយតបរបស់លោក អៀង សារីទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D390/1/2/1.3។

[១៣] *ដូចខាងលើ,* កថាខណ្ឌ ៣២ ដល់៣៣។

[១៤] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D427 កថាខណ្ឌ ១៣១៣ ដល់១៥, ១៣៥០ ដល់ ១៤៧៨, ១៦១៣។

[១៥] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ ឯកសារលេខ D427/1/6។

[១៦] *ដូចខាងលើ,* កថាខណ្ឌ ១៨៨ ដល់៨៩។

៧. នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ ក.ស.ព បានដាក់ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ [១៧]។ ក.ស.ព បានសន្និដ្ឋានថា "ការហាមឃាត់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ... មិនតម្រូវឲ្យមានចំណងទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ឡើយ" [១៨]។

៨. នៅថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១០ មេធាវីការពារក្តីបានដាក់សារណាឆ្លើយតបរបស់ខ្លួនទៅនឹងចម្លើយតបរួមរបស់ ក.ស.ព [១៩]។ មេធាវីការពារក្តីបានលើកឡើងយ៉ាងជាក់លាក់អំពីថាតើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឲ្យមានចំណងទាក់ទងនឹងជម្លោះប្រដាប់អាវុធ ក្នុងអំឡុងពេលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ឬទេ ដោយធ្វើការសន្និដ្ឋានជាថ្មីម្តងទៀតថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិមានបញ្ចូលចំណងទំនាក់ទំនងនេះក្នុងពេលនោះ [២០]។

៩. នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ដោយមានចេញសំអាងហេតុនាពេលក្រោយមកទៀត [២១] និងសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ដោយមានចេញសំអាងហេតុនាពេលក្រោយ [២២]។ នៅក្នុងសាលដីកាទាំងពីរនេះ អង្គបុរេជំនុំជម្រះបាន

---

[១៧] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ ឯកសារលេខ D427/3/6, កថាខណ្ឌ ១៧៥ ដល់៨៥។

[១៨] *ដូចខាងលើ,* កថាខណ្ឌ ១៧៥ ដល់៨៥។

[១៩] សារណាឆ្លើយតបរបស់ អៀង សារី ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១០ ឯកសារលេខ D427/1/23។

[២០] *ដូចខាងលើ,* កថាខណ្ឌ ៨៦ ដល់៩៣។

[២១] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/1/26។

[២២] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/2/12 និង D427/3/12។

សម្រេចថា ក.ស.ច.ស មានកំហុសដោយមិនបានបញ្ចូលចំណងទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងដីកាដំណោះស្រាយ[២៣]។

១០. នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង។

១១. នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានចេញសំអាងហេតុសម្រាប់សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ[២៤] ក្នុងនោះមានមូលហេតុមួយចំនួនគាំទ្រដល់ការយល់ឃើញរបស់ខ្លួនថា ក.ស.ច.ស មានការកំហុសដោយខកខានមិនបានបញ្ចូលលក្ខខណ្ឌតម្រូវនៃចំណងទាក់ទងនឹងជម្លោះប្រដាប់អាវុធជាផ្នែកនៃនិយមន័យរបស់ខ្លួននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[២៥]។ អង្គបុរេជំនុំជម្រះអង្កេតឃើញថា "ទោះបី អង្គជំនុំជម្រះសាលាដំបូងមិនបានធ្វើការសន្និដ្ឋានក្នុងសាលក្រមលើរឿងក្តី *០០១* ទាក់ទិននឹងការណ៍ដែលអង្គជំនុំជម្រះនេះយកឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមកអនុវត្តនៅក្នុងករណីនេះក៏ដោយ ក៏អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា បញ្ហាអត្ថិភាពនៃលក្ខខណ្ឌតម្រូវជម្លោះប្រដាប់អាវុធមិនត្រូវបានជំទាស់ជាក់លាក់ដោយជនជាប់ចោទទេ ហេតុនេះហើយវាមិនមែនជាបញ្ហាដែលអង្គបុរេជំនុំជម្រះត្រូវដោះស្រាយឡើយ"[២៦]។

១២. នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានចេញសំអាងហេតុសម្រាប់សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ[២៧]។ អង្គបុរេជំនុំជម្រះបានសម្រេចថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងធម្មនុញ្ញ IMT និង គោលការណ៍ Nuremberg ដែលក្នុងនោះមានទាំងទំនាក់ទំនងជាមួយនឹងឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព ឬឧក្រិដ្ឋកម្មសង្គ្រាម នៅតែបន្តអនុវត្តនៅក្នុងចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដោយមានបន្ថែមទាំងលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធ ទៅនឹងលក្ខខណ្ឌតម្រូវ "រួម" នៃឧក្រិដ្ឋកម្ម

---

[២៣] *ដូចខាងលើ*

[២៤] សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ D427/3/15។

[២៥] *ដូចខាងលើ*, កថាខណ្ឌ ១៤៤។

[២៦] *ដូចខាងលើ*

[២៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D427/1/26។

ប្រឆាំងមនុស្សជាតិក្នុងដីកាដំណោះស្រាយ [២៨]។ អង្គបុរេជំនុំជម្រះបានធ្វើការកត់សម្គាល់បន្ថែមដូចខាងក្រោម ៖

ក. ធម្មនុញ្ញតុលាការ IMT និងគោលការណ៍ Nuremberg មានចែងពីលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងជម្លោះប្រដាប់អាវុធ[២៩]។

ខ. អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY នៅក្នុង *រឿងក្តី Tadić* ដែលបានសម្រេចថាលក្ខខណ្ឌតម្រូវទាក់ទងមានអត្ថិភាពតែនៅក្នុងបរិបទ Nuremberg ប៉ុណ្ណោះ មានតម្លៃតិចតួចពីព្រោះរឿងក្តីនានាដែលតុលាការ ICTY នេះដោះស្រាយ "ទាក់ទិននឹងពេលវេលាមួយដែលខុសពីពេលវេលានៃយុត្តាធិការរបស់ អ.វ.ត.ក"[៣០]។

គ. អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក្នុងរឿងក្តី *Tadić* នៅក្នុងសេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីស្តីពីយុត្តាធិការ បានដកស្រង់រឿងក្តី *Einsatzgruppen* ដើម្បីគាំទ្រដល់សំណើដែលថា ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង មិនបានបញ្ចូលទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធទេ [៣១] ប៉ុន្តែ "មិនបាននិយាយដល់យុត្តិសាស្ត្រក្រោយរបស់តុលាការយោធាអន្តរជាតិដែលបានបញ្ជាក់សាជាថ្មីពីទំនាក់ទំនងនៃសង្គ្រាម"[៣២]។

ឃ. បញ្ញត្តិនានាពីមុននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្អែកលើច្បាប់ និងទំនៀមទម្លាប់នៃសង្គ្រាម[៣៣] រួមទាំងបុព្វកថានៃសេចក្តីប្រកាសនៅទីក្រុង St. Petersburg នៅក្នុងឆ្នាំ ១៨៦៨ និង Martens Clause នៅក្នុងអនុសញ្ញាទីក្រុងឡាអេ (II) និង (IV) ដូចនេះ អ្នកធ្វើសេចក្តីព្រាងនៃធម្មនុញ្ញ IMT បានបញ្ចូលទំនាក់ទំនងមួយ ដើម្បីធានាថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្ថិតនៅក្នុងក្របខណ្ឌនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ[៣៤]។

---

[២៨] *ដូចខាងលើ,* កថាខណ្ឌ ៣១៣។

[២៩] *ដូចខាងលើ,* កថាខណ្ឌ ៣០៦។

[៣០] *ដូចខាងលើ,* កថាខណ្ឌ ៣០៧។

[៣១] *ដូចខាងលើ,* កថាខណ្ឌ ៣០៨។

[៣២] *ដូចខាងលើ*

[៣៣] *ដូចខាងលើ*

[៣៤] *ដូចខាងលើ*

ង. វាមិនបានបង្ហាញឲ្យបានច្បាស់លាស់ទេថាតើទំនាក់ទំនងនេះត្រូវបានកាត់ផ្ដាច់មុនពេល ឬក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ៖

១. ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង គឺជាច្បាប់ជាតិជាពិសេស ...”[៣៥]។

២. អនុសញ្ញាស្ដីអំពីអំពើប្រល័យពូជសាសន៍ ឆ្នាំ ១៩៤៨ មិនបានបញ្ចូលលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងប្រដាប់អាវុធទៅក្នុងនិយមន័យប្រល័យពូជសាសន៍ទេ ហើយអនុសញ្ញានេះត្រូវបានអនុម័តជាឯកច្ឆន្ទដោយមហាសន្និបាតអង្គការសហប្រជាជាតិ[៣៦]។ ទោះជាយ៉ាងនេះក្ដី និយមន័យនៃអំពីប្រល័យពូជសាសន៍មានលក្ខណៈខុសពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពីព្រោះនិយមន័យនេះមានធាតុផ្សំមួយនៃ “ចេតនាជាក់លាក់” ហើយអនុសញ្ញានេះក៏មិនបានផ្លាស់ប្ដូរលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ[៣៧]។

៣. សេចក្ដីព្រាងក្រមស្ដីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ ឆ្នាំ ១៩៥៤ ដែលបានកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយមិនបញ្ចូលទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធ មិនត្រូវបានអនុម័តដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិឡើយ[៣៨]។

៤. អនុសញ្ញាស្ដីពីអាជ្ញាយុកាល ឆ្នាំ ១៩៦៨ ដែលបានកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយគ្មានទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធ ត្រូវបានចុះហត្ថលេខា, ផ្ដល់សច្ចាប័ន ឬចូលជាសមាជិក ដោយរដ្ឋជាសមាជិកចំនួនតែ ១៨ ប៉ុណ្ណោះ ក្នុងចំណោមរដ្ឋ ១៣៤ នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដែលនេះបង្ហាញថា វាមិនមែនជាការអនុវត្តរបស់រដ្ឋទូទៅឡើយ[៣៩]។

---

[៣៥] *ដូចខាងលើ*, កថាខណ្ឌ ៣០៩។

[៣៦] *ដូចខាងលើ*

[៣៧] *ដូចខាងលើ*

[៣៨] *ដូចខាងលើ*

[៣៩] *ដូចខាងលើ*

៥. អនុសញ្ញាស្តីពីការប្រកាន់ពូជសាសន៍ដែលកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយមិនមានលក្ខខណ្ឌតម្រូវនៃចំណងទាក់ទង ត្រូវបានចុះហត្ថលេខា ផ្តល់សច្ចាប័ន ឬចូលជាសមាជិកដោយសមាជិកចំនួន ២៥ ក្នុងចំណោមសមាជិករបស់អង្គការសហប្រជាជាតិទាំង ១៣៤ មកត្រឹមថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងមានរដ្ឋចំនួន ៣២ ទៀតក្នុងចំណោមរដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិចំនួន ១៤៨ នៅត្រឹមឆ្នាំ ១៩៧៩[៤០]។ ជាងនេះទៀត ការដកចេញនូវលក្ខខណ្ឌនៃចំណងទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ មិនផ្លាស់ប្តូរលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធមួយចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងអស់ផ្សេងៗទៀតទេ[៤១]។

ច. វានៅតែមិនទាន់ច្បាស់លាស់នៅឡើយថា តើពេលណាមានការបំបែកលក្ខខណ្ឌចំណងពាក់ព័ន្ធ ហើយ "បើតាមគោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* (*in dubio pro reo*) ភាពមិនច្បាស់លាស់បែបនេះនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ"[៤២]។

១៣. នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ ក.ស.ព បានដាក់បញ្ជីបញ្ហាច្បាប់ដែលខ្លួនមានបំណងចង់លើកនៅពេលសវនាការបឋម[៤៣]។ នៅក្នុងបញ្ជីនេះ ក.ស.ព បានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថា ខ្លួននឹង "*ស្នើសុំធ្វើការកំណត់បទចោទសាជាថ្មីនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយបញ្ចូល៖* (ក) ថា ជម្លោះប្រដាប់អាវុធមិនតម្រូវឲ្យមានការបង្ហាញសក្ខីកម្មអំពីឧក្រិដ្ឋកម្មណាមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ ..."[៤៤]។

១៤. នៅថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១១ មេធាវីការពារក្តីបានដាក់ការសង្កេតលើបញ្ជីបញ្ហាអង្គច្បាប់របស់ ក.ស.ព ដោយលើកទឡ្ហីករណ៍ថា យោងតាមវិធាន ៨៩ ក.ស.ព ត្រូវបានរារាំងដោយពេលវេលា

---

[៤០] *ដូចខាងលើ*

[៤១] *ដូចខាងលើ*

[៤២] *ដូចខាងលើ*, កថាខណ្ឌ ៣១០។

[៤៣] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីបញ្ហាច្បាប់ដែលខ្លួនមានបំណងចង់លើកនៅពេលសវនាការបឋម ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ E9/30។

[៤៤] *ដូចខាងលើ*, កថាខណ្ឌ ១(៩)។

កំណត់មិនឲ្យលើកបញ្ហាទាំងនេះទៀតទេ[៤៥]។ ជាងនេះទៀត បើទោះបីជាបញ្ហាទាំងនេះមិនត្រូវបានរារាំងដោយពេលវេលាកំណត់ក៏ដោយ "ក៏វិធាន ៩៨ មិនអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការកំណត់បទចោទជាថ្មីឡើយ"[៤៦]។

១៥. នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ក.ស.ព បានឆ្លើយតបទៅនឹង សេចក្តីអង្កេតរបស់ អៀង សារី ដោយបានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីទាំងអស់ថា ខ្លួន "នឹងដាក់សេចក្តីសន្និដ្ឋានដែលស្នើសុំឲ្យធ្វើការកំណត់បទចោទនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរជាថ្មីឡើងវិញនៅក្នុងសាលក្រម" និងខ្លួនមានបំណងដាក់ជូនសេចក្តីសន្និដ្ឋានទាំងនេះ នៅមុនពេលសវនាការបឋម[៤៧]។

១៦. នៅថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១១ មេធាវីការពារក្តី ក្រើនរំឭកអង្គជំនុំជម្រះសាលាដំបូង (តាមរយៈលិខិតមួយដែលបានបញ្ជូនទៅភាគីទាំងអស់) អំពីកង្វល់មួយចំនួន ក្នុងនោះរួមទាំងស្ថានភាពនៃបំណងរបស់ ក.ស.ព ដែលបានស្នើឡើង ដើម្បីដាក់សេចក្តីសន្និដ្ឋានអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[៤៨]។ មេធាវីការពារក្តីបានធ្វើការបញ្ជាក់ជំហររបស់ខ្លួនម្តងទៀតថា ក.ស.ព មិនអាចដាក់សំណើផ្សេងៗស្នើសុំឲ្យកំណត់បទចោទឡើងវិញទេ ពីព្រោះពេលវេលាមិនអនុញ្ញាតឲ្យធ្វើដូចនេះឡើយ។ មេធាវីការពារក្តីបានស្នើអង្គជំនុំជម្រះសាលាដំបូងឲ្យចេញសេចក្តីបង្គាប់មួយសម្រាប់អនុភាពនេះ[៤៩]។

១៧. នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ ក.ស.ព បានដាក់សំណើរបស់ខ្លួន សុំឲ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពី ទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំង

---

[៤៥] ការអង្កេតរបស់ អៀង សារី ចំពោះការជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីបញ្ហាច្បាប់ដែលសហព្រះរាជអាជ្ញាមានបំណងលើកនៅសវនាការបឋម ឯកសារលេខ E9/30/1។

[៤៦] *ដូចខាងលើ*

[៤៧] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹង "សេចក្តីសង្កេតរបស់ អៀង សារី ចំពោះការជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីបញ្ហាច្បាប់ដែលខ្លួនមានបំណងលើកឡើងនៅពេលសវនាការបឋម" ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ E9/30/2, កថាខណ្ឌ ៣ ដល់ ៤។

[៤៨] លិខិតពីក្រុមមេធាវីការពារក្តីរបស់អៀង សារី ផ្ញើជូនអង្គជំនុំជម្រះសាលាដំបូង ៖ សំណើសុំព័ត៌មានទាក់ទងនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមអំពីអញ្ញត្រកម្មមួយចំនួន, កម្មវិធីសវនាការ និងព័ត៌មានទាក់ទងនឹងសវនាការបឋម និងស្ថានភាពនៃសំណើនានាដែលការិយាល័យព្រះរាជអាជ្ញាបានស្នើឡើងអំពីសហឧក្រិដ្ឋកម្មរួម III និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១១។

[៤៩] *ដូចខាងលើ*, ទំព័រ ៣។

មនុស្សជាតិ (“សំណើ”)[៥០]។ ក.ស.ព បានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើវិសោធនកម្មលើនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងដីកាដំណោះស្រាយមួយដែលបានកែប្រែ ដោយមិនរាប់បញ្ចូលនូវលក្ខខណ្ឌតម្រូវស្តីពី ទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធដែលអង្គបុរេជំនុំជម្រះបានបន្ថែម[៥១]។ ក.ស.ព លើកទឡ្ហីករណ៍ថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ គឺជាការត្រឹមត្រូវ ហើយបានសន្និដ្ឋានថា **ក.** មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ពុំមានលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធទេ **ខ.** លក្ខខណ្ឌតម្រូវអំពីចំណងទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ពិតជាមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ និង **គ.** “គេអាចព្យាករណ៍ទុកជាមុនថា ជនជាប់ចោទអាចនឹងត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជាក្រៅជម្លោះប្រដាប់អាវុធ ...”[៥២]។

១៨. នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ មេធាវីការពារក្តីបានដាក់ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់ ក.ស.ព សុំឲ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងសំណើឲ្យមានសវនាការផ្ទាល់មាត់ (“ចម្លើយតបទៅនឹងសំណើ”)[៥៣]។ មេធាវីការពារក្តីបានស្នើឲ្យច្រាលចោលសំណើនេះ ពីព្រោះវាគឺជា

---

[៥០] សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E95។

[៥១] *ដូចខាងលើ*, កថាខណ្ឌ ១។

[៥២] *ដូចខាងលើ*, កថាខណ្ឌ ២។ បន្ទាប់ពីសំណើនេះ នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១ មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបានផ្ញើសារអេឡិចត្រូនិកមួយជូនភាគីទាំងអស់ដោយធ្វើការបញ្ជាក់ថា ក្រុមមេធាវីការពារក្តីមានរយៈពេលរហូតដល់ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ដើម្បីឆ្លើយតបទៅនឹងសំណើនេះ ហើយថា ការិយាល័យសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេល ១០ ថ្ងៃដើម្បីឆ្លើយតប។ នៅថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១, អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចជាផ្លូវការមួយ (សេចក្តីសម្រេចលើការពន្យារពេលវេលា ឯកសារលេខ E107), ដែលបានធ្វើការកែតម្រូវសារអេឡិចត្រូនិកនេះដោយធ្វើការបញ្ជាក់ថា ក្រុមមេធាវីការពារក្តី និងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលរហូតដល់ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ដើម្បីឆ្លើយតប ហើយការិយាល័យសហព្រះរាជអាជ្ញាអាចឆ្លើយតប នៅត្រឹមថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១១។

[៥៣] ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងសំណើសុំបើកសវនាការស្ដួរ

អញ្ញត្រកម្មខុសពេលវេលា ទាក់ទងនឹងយុត្តាធិការនៃអង្គជំនុំជម្រះសាលាដំបូង[៥៤] ។ ម្យ៉ាងវិញទៀត មេធាវីការពារក្ដីបានអះអាងថា សំណើនេះពុំមានសុពលភាពឡើយ ពីព្រោះបញ្ហាជម្លោះប្រដាប់អាវុធ ត្រូវបានរងការប្ដឹងតវ៉ាយ៉ាងច្រើន ហើយសំណើនេះមិនបានបង្ហាញនូវកំហុសណាមួយនៅក្នុងសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ (ថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងដីកាដំណោះស្រាយចាំបាច់ត្រូវមានចំណងទាក់ទងនឹងជម្លោះប្រដាប់អាវុធ) ដែលតម្រូវឲ្យមានការកែប្រែ[៥៥] ។ ជាងនេះទៀត មេធាវីការពារក្ដី អៀង សារី បានបញ្ជាក់ទៀតថា លក្ខខណ្ឌតម្រូវនៃទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ មានអាត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[៥៦]។

១៩. នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង (“ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី”)[៥៧]។ អង្គជំនុំជម្រះសាលាដំបូងបំបែកកិច្ចដំណើការនីតិវិធីក្នុងសំណុំរឿង 00២ ទៅជាការជំនុំជម្រះដោយឡែកៗ ដោយសវនាការដំណាក់កាលនីមួយៗលើកយកផ្នែកផ្សេងៗនៃដីកាដំណោះស្រាយមកធ្វើសវនាការ[៥៨]។

---

ដេញដោលផ្ទាល់មាត់ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារលេខ E95/4។ ក្រុមមេធាវីការពារក្ដីទាំងអស់បានដាក់ចម្លើយតបទៅនឹងសំណើនេះ; *មើល* ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះសាលាដំបូងកែប្រែនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, (អៀង ធីរិទ្ធ), ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារលេខ E95/2; ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាដែលបានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងលុបចោលនូវលក្ខណវិនិច្ឆ័យដែលដាក់បញ្ចូលជម្លោះប្រដាប់អាវុធទៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ខៀវ សំផន), ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១, E95/3; ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យ អង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្ដីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, (នួន ជា), ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារលេខ E95/5។

៥៤ *ដូចខាងលើ*, កថាខណ្ឌ ១៤។

៥៥ *ដូចខាងលើ*, សេចក្ដីផ្ដើម។

៥៦ *ដូចខាងលើ*, កថាខណ្ឌ ២១ ដល់ ២២។

៥៧ ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារលេខ E124។

៥៨ *ដូចខាងលើ*, កថាខណ្ឌ ២ ដល់ ៦។

២០. នៅថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ("ដីការងការជំទាស់")[៥៩]។ អង្គជំនុំជម្រះសាលាដំបូងរកឃើញថា សំណើរបស់ ក.ស.ព អាចទទួលយកបាន[៦០] និង "បានតម្កល់ការយល់ឃើញលើកមុនរបស់ខ្លួនក្នុងសំណុំរឿង ០០១ ដែលថា ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធពុំមែនជាផ្នែកមួយនៃនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅចន្លោះពីឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩ ឡើយ" [៦១] ដោយទទួលយកតាមសំណើ និងដកចេញលក្ខខណ្ឌតម្រូវនៃទំនាក់ទងទៅនឹងជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងសំណុំរឿង ០០២[៦២]។ អង្គជំនុំជម្រះសាលាដំបូងមិនបានលើកឡើងពីសំអាងហេតុផ្លូវច្បាប់របស់អង្គបុរេជំនុំជម្រះនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារីប្រឆាំងនឹងដីកាដំណោះស្រាយ[៦៣] ក្នុងនោះរួមទាំងការអនុវត្តគោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ (in dubio pro reo)* ចំពោះបញ្ហាទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធ[៦៤]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ឡើងវិញអំពីទទ្ទឹករណ៍របស់ខ្លួនពីសំណុំរឿង ០០១ និងផ្អែកលើ **ក.** ច្បាប់

---

[៥៩] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ E95/8។

[៦០] *ដូចខាងលើ*, កថាខណ្ឌ ៩។

[៦១] *ដូចខាងលើ*, កថាខណ្ឌ ៣៣។

[៦២] *ដូចខាងលើ*, ទំព័រ ១៥។

[៦៣] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D427/1/26។

[៦៤] *ដូចខាងលើ*, កថាខណ្ឌ ៣១០ ដល់ ១១។ អង្គបុរេជំនុំជម្រះបានសម្រេចថា "ដោយសារមិនមានទម្លាប់អនុវត្តច្បាស់លាស់ និងទស្សនៈច្បាប់នោះ (*opinio juris*), អង្គបុរេជំនុំជម្រះ ... នៅតែមិនអាចកំណត់បានពីដំណាក់កាលដែលមានបញ្ហា ... នៅពេលដែលដំណាក់កាលអន្តរកាល [ទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធ] បានកើតឡើង។ បើតាមគោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* (*in dubio pro reo*), ភាពមិនច្បាស់លាស់បែបនេះនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ដូចនេះ អង្គបុរេជំនុំជម្រះសម្រេចថានិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងធម្មនុញ្ញតុលាការ Nuremberg និងគោលការណ៍ Nuremberg បន្តអនុវត្តនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ហើយថាចំណងទាក់ទងមួយទៅនឹងឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព ឬឧក្រិដ្ឋកម្មសង្គ្រាមនៅតែជាធាតុផ្សំមួយដ៏សំខាន់នៅឡើយ"។

លេខ ១០របស់ក្រុមប្រឹក្សាត្រួតពិនិត្យ ឆ្នាំ ១៩៤៥[៦៥] **ខ.** អនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឆ្នាំ ១៩៤៨[៦៦] គ. សេចក្តីព្រាងក្រមស្តីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខមនុស្សជាតិរបស់គណៈកម្មាធិការច្បាប់អន្តរជាតិ ឆ្នាំ ១៩៥៤[៦៧] **ឃ.** អនុសញ្ញាស្តីពីភាពមិនអាចអនុវត្តបាននៃអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឆ្នាំ ១៩៦៨[៦៨] **ង.** អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាប និងការផ្តន្ទាទោសលើឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍ ឆ្នាំ១៩៧៣[៦៩] និង **ច.** អង្គជំនុំជម្រះផ្សេងៗនាពេលបច្ចុប្បន្ន[៧០]។ ជាងនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានសម្រេចដោយផ្អែកលើយុត្តិសាស្ត្រ អនុលោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាត្រួតពិនិត្យ[៧១]។

២១. នៅថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១ មេធាវីការពារក្តីបានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងអំពីបំណងរបស់ខ្លួនក្នុងការដាក់បណ្តឹងឧទ្ធរណ៍នេះតាមរយៈសំណើរបស់ខ្លួនសុំផ្អាកការអនុវត្ត "សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ"[៧២]។

---

[៦៥] ដីការងការជំទាស់, កថាខណ្ឌ ១៥។

[៦៦] *ដូចខាងលើ,* កថាខណ្ឌ ២៤ ដល់ ២៥។

[៦៧] *ដូចខាងលើ,* កថាខណ្ឌ ១២ ដល់ ២៣។

[68] *ដូចខាងលើ,* កថាខណ្ឌ ២៦ ដល់ ២៩។

[៦៩] *ដូចខាងលើ,* កថាខណ្ឌ ៣០។

[៧០] *ដូចខាងលើ,* កថាខណ្ឌ ៣១ ដល់ ៣២។

[៧១] *ដូចខាងលើ,* កថាខណ្ឌ ១៥ ដល់ ២០។

[៧២] សំណើរបស់លោក អៀង សារី សុំផ្អាកការអនុវត្ត "សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារលេខ E134។